## អតិសុខុមប្រាណ (Micro-organisms)

សារពាង្គកាយមានជីវិតភាគច្រើន ដូចជា រុក្ខជាតិ សត្វ មនុស្ស គឺធំគ្រប់គ្រាន់ដែលអាចមើលដោយភ្នែកទទេបាន។ សារពាង្គកាយមានជីវិតផ្សេងទៀត គឺតូចដែលត្រូវការអតិសុខុមទស្សន៍ដែលមានអនុភាពខ្ពស់ដើម្បីអាចមើលពួកវាឃើញ សារពាង្គកាយទាំងនោះ ត្រូវបានគេហៅថា អតិសុខុមប្រាណ។ មាន ៥ប្រភេទនៃអតិសុខុមប្រាណដែលមានជីវិត ពួកវាគឺ:

- **បាក់តេរី (bacteria)**--គឺជាសារពាង្គកាយមានកោសិកាទោលរាងមូល រឺស័ររឺ ដំបង។ ឧទាហរណ៏រួមមាន Salmonella ដែលបង្កអោយអាហារមានភាពស្អិតស្អេរ, Streptococcus pyrogenes ដែលបណ្តាលអោយឈឺបំពង់ក, Streptococcus Mutan ដែលធ្វើឱ្យមានរោគពុកធ្មេញ។
- **វីរុស (viruses)**--គឺជាបរាសិត ដែលមានន័យថាវាអាចរស់បានតែនៅក្នុងកោសិកា នៃភាវៈរស់មានជីវិតដទៃទៀតប៉ុណ្ណោះ។ ពួកវាបង្កជំងឺឆ្លងយ៉ាងខ្លាំង ដូចជា អុតធំ កញ្ជ្រឹល រលាកភ្នែក (conjunctivitis)។ វីរុសជាអតិសុខុមប្រាណដែលតូចបំផុត ហើយអាចមើលឃើញដោយមីក្រូទស្សន៍ដែលមានអនុភាពខ្លាំង។ នៅក្នុងវិស័យទន្តសាស្ត្រ យើងត្រូវស្គាល់ពី ការរលាកថ្លើមប្រភេទ B (Hepatitis B) និង ជំងឺអេដស៏ (Human Immunodeficiency Virus: HIV) ដែលសាយភាយតាមទឹកជាលិកា ដូចជា ឈាម និង ទឹកមាត់។
- **ផ្សិត (fungi)**--អាចមានទំហំខុសៗគ្នាច្រើនដែលមានចាប់ពី មេដំបែ (yeast) ដែលមានកោសិកាតែមួយមើលឃើញដោយមីក្រូទស្សន៍ ដែលគេប្រើក្នុងការផលិតនំប៉័ង និង ស្រាបៀរ រហូតដល់ពពួកផ្សិតដែលអាចមើលឃើញតាមម៉ាក្រូទស្សន៍ដែលមានកោសិកាច្រើនដូចជា ពពួកផ្សិតដែលធ្វើអោយធាតុសរីរាង្គពុកផុយ ផ្សិតយកមកបរិភោគ និង ផ្សិតពុល។ ក្នុងវិស័យទន្តសាស្ត្រ យើងមានពពួក Candida Albicans ដែលបង្កអោយមានការបង្ករោគនៅក្រោមធ្មេញស្និត ឬ បន្ទះសនៅក្នុងមាត់លើអ្នកជំងឺណាដែលឈឺធ្ងន់។
- **Algae**--អាចមានទំហំខុសៗគ្នាជាច្រើន ចាប់ពី alga ដែលមានកោសិកាតែមួយអាចមើលឃើញតាមរយៈមីក្រូទស្សន៍ ដែលគេប្រើក្នុងថ្នាំដុសធ្មេញ រហូតដល់ algae ដែលមើលឃើញតាមរយៈម៉ាក្រូទស្សន៍ដែលមានផ្ទុកកោសិកាជាច្រើន ដូចជាពពួករុក្ខជាតិសមុទ្រ។
- **ប្រូតូសូអ៊ែរ (protozoa)**--ជាសារពាង្គកាយដែលមានកោសិកាតែមួយដែលអាចបង្កជំងឺដូចជាគ្រុនចាញ់ និង ជំងឺដេកមិនបាន (sleeping sickness)។ ពួកវាក៏អាចមានប្រយោជន៏ ឧទាហរណ៏ដូចជា ក្នុងការធ្វើប្រព្រឹត្តិកម្មកាកសំណល់ពីលំនៅដ្ឋានដែលប្រូតូសូអ៊ែរអាចស៊ីកំទេចបាក់តេរីចង្រៃ ដោយធ្វើអោយកាកសំណល់ទាំងនោះមានសុវត្ថិភាពក្នុងការយកទៅបោះចោល។
- **ស្ប៉ (spores)**--ជាកោសិកា រឺ សារពាង្គកាយតូចៗណាមួយ ដែលអាចវិវត្តន៏ទៅជាសារពាង្គកាយថ្មីមួយទៀតបាន; គ្រាប់ពូជថ្មី រឺ អតិសុខុមប្រាណដែលបង្កជំងឺ។

**<u>Hepatitis</u> -- (រលាកថ្លើម)**

វីរុសអាចបណ្តាលឱ្យមានជំងឺ មានដូចជា រលាកថ្លើមប្រភេទ A, B និង C។

**រលាកថ្លើមប្រភេទ A**--គឺជាជំងឺឆ្លងខ្លាំង ដែលបង្កឡើងពីវីរុសរលាកថ្លើម។ វាច្រើនកើតពាសពេញពិភពលោក ជាពិសេសនៅកន្លែងដែលខ្វះអនាម័យ។ មុនដំបូង មានការក្តៅខ្លួន អស់កំលាំង ចុះទំងន់ ចង្អោរ និង មានការចុកពោះ ជាធម្មតាក្រោយមកនឹងមានកើតខាន់លឿង ក្នុងអំឡុងពេល ពីរបីថ្ងៃ។ ជំងឺនេះ ជាធម្មតា ស្រាល ហើយអ្នកជំងឺអាចសង្ឃឹមជាសះស្បើយឡើងវិញទាំងស្រុង។

ជំងឺរលាកថ្លើមប្រភេទ A សាយភាយតាមរយៈចំណីអាហារ និង ទឹក ដែលបានធ្វើអោយកខ្វក់ដោយលាមក។ អ្នកជំងឺដែលឆ្លងដោយវីរុសនេះបញ្ចេញវីរុសប្រភេទនេះ ដែលអាចឆ្លងបាន (អាចចំលងជំងឺនេះទៅបុគ្គលដទៃទៀត) ក្នុងរយៈពេល ២ ទៅ ៣ សប្តាហ៏ មុនពេលចាប់ផ្តើមនៃជំងឺនេះ ហើយអាចបន្តទៅពីរសប្តាហ៏ក្រោយទៀត។ អំឡុងពេលនេះ កង្វះអនាម័យដូចជា មិនបានលាងដៃក្រោយពេលចេញពីបង្គន់ រឺ មិនលាងដៃមុនពេលចាប់កាន់អាហារ អាចចម្លងវីរុសនេះ។ ដោយសារជំងឺរលាកថ្លើមប្រភេទ A ឆ្លងតាមរយៈលាមកអាហារ និង ទឹកកខ្វក់ នោះការចំលងនៅក្នុងការវះកាត់ធ្មេញមិនទំនងជាមានទេ។

**ជំងឺរលាកថ្លើមប្រភេទ B**--គឺជាជំងឺធ្ងន់ធ្ងរខ្លាំងជាងជំងឺរលាកថ្លើមប្រភេទ A។ វាបណ្តាលមកពី វីរុសរលាកថ្លើមប្រភេទ B។ ដំបូងអាចមានការចុះទំងន់ ចង្អោរ ក្អួត ចុកពោះ ឡើងកន្ទួលលើស្បែក និង ឈឺសន្លាក់។ ការក្តៅខ្លួនមិនប្រាកដអាចកើតមានឡើងទេ ហើយខាន់លឿង កើតឡើងនៅពេលក្រោយមក។ មិនដូចរលាកថ្លើមប្រភេទ A ដែលវាអាចជាសះស្បើយទាំងស្រុង អ្នកជំងឺមួយចំនួនដែលរលាកថ្លើមប្រភេទ B វិវត្តន៏ទៅជារលាកថ្លើមរ៉ាំរ៉ៃ ហើយអាចនឹងបន្តមានមេរោគស្ថិតនៅក្នុងឈាមរបស់ពួកគេក្នុងរយៈពេលមួយដ៏យូរ រឺ មួយជីវិតក៏មាន។ វីរុសនេះស្ថិតនៅក្នុងខ្លួនអ្នកជំងឺ ថ្វីបើអ្នកជំងឺនោះគ្មានរោគសញ្ញាណាមួយនៃជំងឺនោះក៏ដោយ។ អ្នកដែលផ្ទុកជំងឺប្រភេទនេះ គឺជាប្រភពចំបងនៃការចំលងទៅអ្នកដទៃ។

វីរុសរលាកថ្លើមប្រភេទ B (HBV) ត្រូវបានឆ្លងដោយការប៉ះពាល់ជាមួយជាលិកាដែលមានជំងឺ រួមមាន ឈាម និង សារធាតុរាវដែលចេញពីរាងកាយដទៃទៀត។ នៅក្នុងការវះកាត់ធ្មេញ ការប៉ះពាល់ដោយចៃដន្យទៅនឹង ឈាម ទឹកមាត់ និង សារធាតុរាវរបស់រាងកាយនៃអ្នកជំងឺដែលមានរោគ អាចចំលងវីរុសនេះ។ អ្នកជំងឺដែលបានបង្ករោគស្រួចស្រាល ឬ រ៉ាំរ៉ៃ ដោយមាន HBV អាចចំលងទៅអ្នកដទៃទៀតបាន។

ការមុតម្ជុល និង ការរបួសដោយវត្ថុមុតស្រួចដទៃទៀត គឺធ្ងន់ធ្ងរណាស់ ពីព្រោះរបួសដែលជ្រៀតចូលទាំងអស់នោះ (វត្ថុមុតស្រួចចូលតាមស្បែក) មានសក្តានុភាពក្នុងការចំលងវីរុស រួមទាំងវីរុសរលាកថ្លើមប្រភេទ B ផងដែរ។ វីរុសនេះ អាចចំលងតាមរយៈ ការខ្ទាត នៃឈាម រឺ សារធាតុរាវរបស់រាងកាយចូលទៅក្នុង ភ្នែក មាត់ ឬ ច្រមុះ។

ហានិភ័យនៃការចំលងរបស់ HBV ពីអ្នកជំងឺទៅបុគ្គលិក (ដែលមិនបានចាក់វ៉ាក់សាំងការពារ HBV) បន្ទាប់ពីគ្រោះថ្នាក់មុតម្ជុលអាស្រ័យទៅលើកំរិតឈាមនៃ HBV របស់អ្នកជំងឺដែលមានផ្ទុកជំងឺនេះ។

**រលាកថ្លើមប្រភេទ C**--ការបង្ករោគនេះ គឺជាក្តីបារម្ភដែលកំពុងកើនឡើងសំរាប់បុគ្គលិកថែទាំសុខភាព។ វាបណ្តាលមកពីការឆ្លង ជាមួយវីរុសរលាកថ្លើមប្រភេទ C និង បង្ករោគសញ្ញាដូចជា ចង្អោរ អស់កំលាំង ខាន់លឿង និង ចុកពោះ ស្រដៀងគ្នាទៅនឹងជំងឺរលាកថ្លើមប្រភេទផ្សេងទៀតដែរ។

ចំពោះអ្នកជំងឺជាច្រើន ជំងឺរលាកថ្លើមប្រភេទ C គឺជាជំងឺមានរយៈពេលវែង និង រ៉ាំរ៉ៃ ដែលអាចអោយលទ្ធផលជាបន្តបន្ទាប់ទៅជាការវិវត្តន៏នៃ ជំងឺថ្លើមរ៉ាំរ៉ៃ ក្រិនថ្លើម និង មហារីក។ ឥឡូវនេះ ការរលាកថ្លើមប្រភេទ C គឺជាបុព្វហេតុនាំមុខគេនៃជំងឺថ្លើម។

អ្នកជំងឺមានរោគនេះស្រួចស្រាល រឺ រ៉ាំរ៉ៃ គឺជាប្រភពចំលងដូចគ្នា។ នៅក្នុងការវះកាត់ធ្មេញ វីរុសរលាកថ្លើមប្រភេទ C (HCV) អាចចំលងទៅបុគ្គលិកដោយការប៉ះពាល់ទៅនឹង ឈាម និង សារធាតុរាវរបស់រាងកាយដែលមានជំងឺនេះ។ ជាពិសេស ការប៉ះពាល់បែបនេះគឺធ្ងន់ធ្ងរណាស់ ដោយសារមិនទាន់មានវ៉ាក់សាំងសំរាប់ជំងឺរលាកថ្លើមប្រភេទ C ទេ។

**<u>ជំងឺអេដស៍: Human Immunodeficiency virus (HIV)</u>**

ក្នុងអំឡុងពេល ពីរបីសប្តាហ៍ដំបូងនៃការឆ្លងជំងឺអេដស៍ នោះមានជំងឺរយៈពេលខ្លី។ ដំបូងអាចមាន ការក្តៅខ្លួន ឈឺសន្លាក់ ឈឺក្បាល ចង្អោរ ហើមកូនកណ្តុរ និង មានឡើងកន្ទួលពណ៌ផ្កាឈូកតូចៗ។ បន្ទាប់ពីនេះ វាមិនមានចេញជារោគសញ្ញាអ្វីទេរយៈពេលបីបួនឆ្នាំ។ នៅអំឡុងពេលនេះ វីរុសបន្តធ្វើការវិវត្តន៍ នៅក្នុងគោសិកាឈាមសនៅក្នុងរាងកាយ។

ជាបន្តបន្ទាប់មក ចំនួនដ៏ច្រើននៃភាគល្អិតតូចៗរបស់វីរុសបានផលិតឡើង នឹងចាប់ផ្តើមបំផ្លាញកោសិកាទាំងនេះ លឿនជាងប្រពន្ធ័ភាពស៊ាំការពាររាងកាយបង្កើតវាទៅទៀត។ គោលិកាឈាមសទាំងនេះ គឺមានសារៈសំខាន់សំរាប់មុខងារធម្មតានៃប្រព័ន្ធភាពស៊ាំ ដែលជាភ្នាក់ងារការពាររាងកាយប្រឆាំងនឹងជំងឺ។ នៅពេលដែល ប្រព័ន្ធភាពស៊ាំត្រូវបានធ្វើអោយខូចខាត អ្នកជំងឺផ្ទុកមេរោគនោះ ងាយនឹងទទួលរងគ្រោះនឹងជំងឺផ្សេងៗ។ នេះរួមមានជំងឺបង្ករោគផ្សេងៗ និង ជំងឺមហារីក។

រោគសញ្ញាដំបូងនៃការបង្ករោគដោយជំងឺអេដស៍ ជារឿយៗច្រើនតែលេចឡើងនៅក្នុងមាត់ ដោយអ្នកជំងឺមានការវិវត្តជាច្រើននូវ ផ្សិត វីរុស និង បាក់តេរីបង្ករោគ។ ការព្យាបាលធ្មេញទូទៅ មិនគួរចៀសវាងឡើយ ពីព្រោះហេតុផលសាមញ្ញគឺ អ្នកជំងឺមានផ្ទុកមេរោគអេដស៍ ជាពិសេស ដោយសារការធ្វើអនាម័យមាត់អោយបានល្អ អាចជួយពន្យាការវិវត្តន៍នៃការបង្ករោគនៅក្នុងមាត់ដ៏ធ្ងន់ធ្ងរ។

**នៅក្នុងគ្លីនិចធ្មេញ សុខភាពអ្នកជំងឺ មិនគួរប៉ះពាល់ដល់របៀបដែលគ្លីនិចនោះត្រូវបានគេរៀបចំ រឺ សំអាតទេ។ ដំណើរការនៃការទប់ស្កាត់ការចំលងមេរោគជាលក្ខណៈស្តង់ដា គួរតែធ្វើឡើងសំរាប់អ្នកជំងឺទាំងអស់។**